**សលាកប័ត្រព័ត៌មាន៖** កម្រងសេរីភាពជាមូលដ្ឋាន៖ សិទ្ធិចូលរួម

**សេរីភាពជាមូលដ្ឋាន៖** សិទ្ធិចូលរួមយ៉ាងសកម្មក្នុងជីវភាពរបស់ប្រទេសជាតិ

**ទិដ្ឋភាពរួម៖** សេចក្តីព្រាងច្បាប់សំខាន់ៗ ពាក់ព័ន្ធនឹងសិទ្ធិមនុស្ស ត្រូវបានបញ្ជូន ឬត្រៀមនឹងបញ្ជូនទៅកាន់រដ្ឋសភាដើម្បីអនុម័ត។ យ៉ាងណាក្តី សេចក្តីព្រាងច្បាប់ថ្មីៗទាំងនោះ មិនត្រូវបានផ្សព្វផ្សាយ ហើយគ្មានការពិគ្រោះយោបល់ជាមួយសង្គមស៊ីវិល និងសាធារណៈជននោះទេ ជាទូទៅ ត្រូវបានរៀបចំឡើងដោយរឹតត្បិតលើសិទ្ធិចូលរួមយ៉ាងសកម្មក្នុងជីវភាពរបស់ប្រទេសជាតិ  និងផ្ទុយទៅនឹងគោលការណ៍អភិបាលកិច្ចល្អទាំងស្រុង។

## សេចក្តីផ្តើម

រាជរដ្ឋាភិបាលកម្ពុជា ("រដ្ឋាភិបាល") បានតាក់តែងសេចក្តីព្រាងច្បាប់សំខាន់ៗ ដែលធ្វើឲ្យប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់សិទ្ធិ និងសេរីភាពរបស់ប្រជាពលរដ្ឋ នៃព្រះរាជាណាចក្រកម្ពុជា ("កម្ពុជា")។  សេចក្តីព្រាងច្បាប់ទាំងនោះ  រួមមាន សេចក្តីព្រាងច្បាប់ស្តីពី ការរៀបចំអង្គការតុលាការ សេចក្តីព្រាងច្បាប់ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅនៃ ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម សេចក្តីព្រាងច្បាប់ស្តីពីលក្ខន្តិកៈនៃចៅក្រម និងព្រះរាជអាជ្ញា សេចក្តីព្រាងច្បាប់ស្តីពី ឧក្រិដ្ឋកម្មលើប្រព័ន្ធបច្ចេកវិទ្យា សេចក្តីព្រាងច្បាប់ស្តីពី សហជីព សេចក្តីព្រាងច្បាប់ស្តីពី សមាគម និងអង្គការមិនមែនរដ្ឋាភិបាល("ច្បាប់សមាគម  និងអង្គការ")។  បើទោះជាមានការអំពាវនាវម្តងហើយម្តងទៀតពីសំណាក់សង្គមស៊ីវិលយ៉ាងណាក៏ដោយ ក៏គ្មានសេចក្តីព្រាងណាមួយ ក្នុងចំណោមសេចក្តីព្រាងច្បាប់ទាំងនោះ ត្រូវបានចេញផ្សាយជាសាធារណៈ ឬបើកកិច្ចពិគ្រោះយោបល់ដោយចំហ និងច្បាស់លាស់នោះទេ  លើកលែងតែសេចក្តីព្រាងច្បាប់ស្តីពី  សមាគម  និងអង្គការដែលបានចេញផ្សាយនៅឆ្នាំ២០១១។  ភាពអាថ៌កំបាំងនៅជុំវិញសេចក្តីព្រាង និងការអនុម័តច្បាប់ទាំងនេះ រឹតត្បិតលើសិទ្ធិចូលរួមយ៉ាងសកម្មរបស់ប្រជាពលរដ្ឋកម្ពុជា ក្នុងជីវភាពទូទៅរបស់ប្រទេសជាតិ ដែលបានធានាដោយរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ("រដ្ឋធម្មនុញ្ញ") និងកាន់តែបង្ហាញពីភាពកង្វះខាតផ្នែកអភិបាលកិច្ចល្អនៅក្នុងស្ថាប័ននានានៅកម្ពុជា។

សលាកប័ត្រព័ត៌មាននេះ តាក់តែងឡើងដោយមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា ("ម.ស.ម.ក") ជាអង្គការឈានមុខ មិនមែនរដ្ឋាភិបាល ឯករាជ្យ មិនចូលបក្សសម្ព័ន្ធ ("អង្គការ") ដែលធ្វើការដើម្បីលើកកម្ពស់លទ្ធិប្រជាធិបតេយ្យ និងគោរពសិទ្ធិមនុស្ស ជាពិសេសសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ នៅទូទាំងប្រទេសកម្ពុជា។

## សិទ្ធិចូលរួមយ៉ាងសកម្មក្នុងជីវភាពរបស់ប្រទេសជាតិ

សិទ្ធិចូលរួមយ៉ាងសកម្មក្នុងជីវភាពរបស់ប្រទេសជាតិ ត្រូវបានធានាក្នុងមាត្រា ៣៥ នៃរដ្ឋធម្មនុញ្ញ ដែលចែងថា "*ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ មានសិទ្ធិចូលរួមយ៉ាងសកម្មក្នុងជីវភាពនយោបាយ សេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌របស់ប្រទេសជាតិ*"។ មាត្រានេះ ពាក់ព័ន្ធគ្នានឹងមាត្រា ២១ (១) នៃ សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស  ("ស.ស.ស.ម")  ដែលចែងថា  "*មនុស្សគ្រប់រូប  មានសិទ្ធិចូលរួមក្នុងការដឹកនាំកិច្ចការសាធារណៈនៃ*

*ប្រទេសរបស់ខ្លួនដោយផ្ទាល់ ឬតាមរយៈតំណាងដែលបានជ្រើសរើសដោយសេរី* ហើយមាត្រា ២៥ នៃកតិកាសញ្ញាអន្តរជាតិស្តីពី សិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ("ក.អ.ស.ព.ន") ចែងថា " *ប្រជាពលរដ្ឋគ្រប់រូបមានសិទ្ធិ និងមានឱកាស [...] ចូលរួមក្នុងការដឹកនាំកិច្ចការសាធារណៈដោយផ្ទាល់ ឬតាមរយៈតំណាង ដែលខ្លួនជ្រើសរើសដោយសេរី*។ ទាំង ស.ស.ស.ម និង ក.អ.ស.ព.ន ត្រូវអនុវត្តដោយផ្ទាល់នៅកម្ពុជាដូចមានចែងតាមមាត្រា ៣១ នៃរដ្ឋធម្មនុញ្ញ។

ទស្សនៈទានជុំវិញអភិបាលកិច្ចល្អ គឺកើតចេញមកពីសិទ្ធិមនុស្សជាសកលទាំងនេះឯង។ យោងតាមអតីតគណៈកម្មាធិការរបស់អង្គការសហប្រជាជាតិទទួលបន្ទុកផ្នែកសិទ្ធិមនុស្សបានបញ្ជាក់ថា ការកំណត់ជាគន្លឹះសំខាន់ជុំវិញអភិបាលកិច្ចល្អ រួមមាន តម្លាភាព ទំនួលខុសត្រូវ គណនេយ្យភាព ការចូលរួម និងការឆ្លើយតបចំពោះតម្រូវការរបស់ប្រជាពលរដ្ឋ។ អភិបាលកិច្ចល្អពឹងផ្អែកលើការចូលរួមប្រកបដោយតម្លាភាព និងច្បាស់លាស់ ហើយមានការពាក់ព័ន្ធជាមួយស្ថាប័ននានារបស់រដ្ឋាភិបាល ដែលផ្តល់នូវវិធីសាស្ត្រ និងមធ្យោបាយងាយស្រួលដើម្បីឲ្យប្រជាពលរដ្ឋបានចូលរួមក្នុងជីវភាពប្រទេសជាតិ ទាំងផ្លូវការ ឬមិនផ្លូវការក្តី។

ដូច្នោះ ទំនួលខុសត្រូវដើម្បីធានាឲ្យមានការចូលរួមជាសាធារណៈ អាស្រ័យទៅលើស្ថាប័នរដ្ឋាភិបាល រួមទាំងរដ្ឋសភាផងដែរ។ ដំណើរការចូលរួមក្នុងការតាក់តែងច្បាប់ ដែលមានលក្ខណៈបើកចំហ និងតម្លាភាព នឹងធ្វើឲ្យនិត្យានុកូលភាព ឯកច្ឆន្ទ រឹងមាំ ព្រមទាំងជួយប្រើប្រាស់យន្តការតាមដាន ត្រួតពិនិត្យ និងទំនួលខុសត្រូវខ្ពស់របស់ប្រជាពលរដ្ឋ និងស្ថាប័ននានា។ កិច្ចពិគ្រោះយោបល់ ក៏អាចជួយពង្រឹងគុណភាពច្បាប់ និងការអនុវត្តន៍ច្បាប់នោះផងដែរ។

នៅក្នុងប្រទេសប្រកាន់របបលទ្ធិប្រជាធិបតេយ្យពិតប្រាកដ ប្រជាពលរដ្ឋនឹងត្រូវបានផ្តល់ឱកាសជូនគ្រប់គ្រាន់ដើម្បីមានមតិយោបល់លើខ្លឹមសារនៃសេចក្តីព្រាងច្បាប់នៅមុនការអនុម័តច្បាប់នោះរបស់រដ្ឋសភា ក្នុងគោលបំណងដើម្បីលើកកម្ពស់សិទ្ធិដែលមានចែងនៅក្នុងរដ្ឋធម្មនុញ្ញ និងច្បាប់សិទ្ធិមនុស្សអន្តរជាតិនានា។

## ភាពអាថ៌កំបាំង និងការផាត់ចេញ៖ ដំណើរការតាក់តែងច្បាប់នៅកម្ពុជា

បើទោះជាមានការអំពាវនាវពីសំណាក់សង្គមស៊ីវិលនោះក្តី រហូតមកទល់នឹងពេលនេះរដ្ឋាភិបាលបដិសេធចេញផ្សាយសេចក្តីព្រាងច្បាប់នានា ហើយបានបដិសេធក្នុងការបើកកិច្ចពិគ្រោះយោបល់លើសេចក្តីព្រាងច្បាប់ថ្មីៗទាំងនោះ។ ផ្ទុយទៅវិញ ជាការឆ្លើយតបទៅនឹងសំណើសង្គមស៊ីវិលដើម្បីឲ្យមានតម្លាភាពជុំវិញសេចក្តីព្រាងច្បាប់ចំនួនបីពាក់ព័ន្ធនឹងវិស័យអង្គការតុលាការនោះ លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន បានមានប្រសាសន៍ នៅថ្ងៃទី២៨ ខែ មេសា ឆ្នាំ២០១៤ ថា រដ្ឋធម្មនុញ្ញមិនអនុញ្ញាតឲ្យរដ្ឋាភិបាលបញ្ជូនច្បាប់ទៅនរណាម្នាក់ក្រៅពីគណៈរដ្ឋមន្ត្រី ដូច្នេះហើយ ប្រសិនបើនរណាមួយ ចង់មានមតិយោបល់លើច្បាប់នេះ ទាល់តែគាត់ជាសមាជិកសភាជាប់ឆ្នោត។ ម .ស.ម.ក មិនឃើញមាត្រាណាមួយក្នុងរដ្ឋធម្មនុញ្ញហាមប្រាមរដ្ឋាភិបាលក្នុងការចែករំលែកសេចក្តីព្រាងច្បាប់ជូនដល់សាធារណៈជននោះទេ។ លើសពីនេះទៀត បន្ទាប់ពីមានសម្ពាធទាំងនៅក្នុងប្រទេស និងអន្តរជាតិ ក្រសួងមហាផ្ទៃបានរៀបចំឲ្យមានការពិគ្រោះយោបល់ជាសាធារណៈពីដំបូងជុំវិញសេចក្តីព្រាងច្បាប់ស្តីពី សមាគម និងអង្គ

ការ។ ដូច្នេះហើយ គ្មានមាត្រាណាក្នុងរដ្ឋធម្មនុញ្ញ រារាំងរដ្ឋាភិបាលក្នុងការទទួលយកមតិយោបល់ពីអង្គការសង្គមស៊ីវិលនោះទេ។ ម្យ៉ាងវិញទៀត ម.ស.ម.ក បានទាក់ទងទៅក្រសួង និងស្ថាប័នពាក់ព័ន្ធផ្សេងៗ ដើម្បីស្នើសុំសេចក្តីព្រាងច្បាប់ដូចបានបញ្ជាក់ជូនខាងលើនោះ ប៉ុន្តែបានទទួលចម្លើយអវិជ្ជមាន។ ស្រដៀងគ្នានេះដែរ នៅថ្ងៃទី០៥ ខែមីនា ឆ្នាំ២០១៤ លោក មាស សារឹម អគ្គនាយករង នៃអគ្គនាយកដ្ឋានរដ្ឋបាលមូលដ្ឋាន នៅក្រសួងមហាផ្ទៃ បានប្រកាសថា រដ្ឋាភិបាលនឹងមិនមានកិច្ចពិគ្រោះយោបល់ជាមួយក្រុមសង្គមស៊ីវិលនោះទេទៅលើកំណែចុងក្រោយបង្អស់នៃសេចក្តីព្រាងច្បាប់ស្តីពី សមាគម និងអង្គការ។

## សេចក្តីសន្និដ្ឋាន

ភាពអាថ៌កំបាំងនៅជុំវិញដំណើរការតាក់តែងច្បាប់ និងការបដិសេធក្នុងការចូលរួម និងបដិសេធក្នុងការបើកកិច្ចពិគ្រោះយោបល់ជាមួយសាធារណៈជន និងសង្គមស៊ីវិល ជាការរំលោភលើសិទ្ធិចូលរួមរបស់ប្រជាពលរដ្ឋក្នុងជីវភាពរបស់ប្រទេសជាតិ ដែលធ្វើឲ្យប៉ះពាល់ធ្ងន់ធ្ងរដល់ភាពស្របច្បាប់នៃស្ថាប័នរបស់រដ្ឋាភិបាល និងកាន់តែបង្ហាញថា ប្រទេសកម្ពុជាមិនត្រូវបានគ្រប់គ្រងស្របតាមគោលការណ៍អភិបាលកិច្ចល្អ និងគោលការណ៍លទ្ធិប្រជាធិបតេយ្យនោះទេ។

ដូច្នេះ ម.ស.ម.ក សូមអោយរដ្ឋាភិបាលគួរអនុម័តច្បាប់ស្តីពី សេរីភាពសារព័ត៌មាន ប្រកបដោយតម្លាភាព ច្បាស់លាស់ និងមានការចូលរួមពីសាធារណៈមតិ បើយោងតាមការប្តេជ្ញាមុនៗរបស់ខ្លួន។ បន្ថែមពីនេះ ម.ស.ម.ក ជឿជាក់ថា នីតិវិធីទៀងទាត់ ត្រូវតែបង្កើតឡើងដើម្បីធានាអោយមានការចូលរួមផ្តល់មតិយោបល់ប្រកបដោយប្រសិទ្ធភាព និងទាន់ពេលវេលាពីសំណាក់ភាគីជាតិ និងអន្តរជាតិ ព្រមទាំងសង្គមស៊ីវិលដែលចាប់អារម្មណ៍ក្នុងដំណើរការនេះផងដែរ។

**សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទង លោកស្រី ចក់ សុភាព នាយិកាប្រតិបត្តិ ម.ស.ម.ក តាមរយៈទូរសព្ទ ៖ +៨៥៥ (០) ១១៩៨៤ ៣២១៣ ឬអ៊ីម៉ែល៖ chaksopheap@cchrcambodia.org ឬលោកស្រី អេលីស ជីលែត ទីប្រឹក្សារបស់ ម.ស.ម.ក តាមរយៈទូរសព្ទ៖ ៖ +៨៥៥ (០) ៧៧៧០ ៩៧២៣ ឬអ៊ីម៉ែល៖ elise.tillet@cchrcambodia.org ។**